00757951

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 12 / 2011
ម៉ោង (Time/Heure) : 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [illegible]

សាធារណៈ / Public

E150

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១

**ជូនចំពោះ:** មេធាវីការពារក្តីជនជាប់ចោទ អៀង សារី

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,ភាគីទាំងអស់នៃសំណុំរឿង ០០២ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងលិខិតរបស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១

យោងលិខិតចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១ របស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ដែលបានផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំឲ្យប្រធានអង្គជំនុំជម្រះសាលាដំបូងចេញអនុស្សរណៈជាផ្លូវការមួយតាងនាមឲ្យអង្គជំនុំជម្រះដោយមានបញ្ជាក់បំភ្លឺអំពីនីតិវិធីរបស់អង្គជំនុំជម្រះក្នុងការសម្រេចលើបណ្តឹង និងសំណើសុំនានា ពិសេសក្នុងករណីដែលបណ្តឹង និងសំណើសុំទាំងនោះ ត្រូវបានផ្ញើមកអង្គជំនុំជម្រះក្នុងលក្ខណៈជាការជូនដំណឹងក្រៅផ្លូវការជាមុនជាភាសាអង់គ្លេស និងជូនដំណឹងជាភាសាខ្មែរនៅពេលបន្ទាប់មក។ លិខិតនេះធ្វើឡើងដោយយោងជាពិសេសទៅលើតារាងពេលវេលាជាក់ស្តែងនៃបណ្តឹងជិតចិត្តមកអង្គជំនុំជម្រះកាលពីពេលថ្មីៗ ដែលការសម្រេចលើបណ្តឹងនេះជាការចាំបាច់ដើម្បីឲ្យអង្គជំនុំជម្រះអាចបញ្ជាក់អំពីសមាសភាពចៅក្រមនៅមុនពេលសវនាការពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២ ដែលនឹងគ្រោងធ្វើនៅថ្ងៃ ច័ន្ទ ទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ខាងមុខ។

E150

ជាការត្រឹមត្រូវ មេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានសង្កេតឃើញថាក្នុងករណីដែលបញ្ហាណាមួយជាបញ្ហាបន្ទាន់ ឬអាចអូសបន្លាយកិច្ចដំណើរការនិតីវិធី អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានោះឲ្យបានឆាប់រហ័ស។ ក្នុងរង្វង់ឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះក៏អាចសម្រេចថាសារណាតប ឬចម្លើយតបរបស់ភាគី ពុំទំនងជាជួយអង្គជំនុំជម្រះឲ្យយល់ដឹងបន្ថែមស្តីអំពីបញ្ហាណាមួយ ពិសេសក្នុងករណីដែលបណ្តឹងទាំងនោះពុំមានលើកបញ្ហាអង្គហេតុ ឬអង្គច្បាប់សំខាន់ៗ ហើយពុំមានលក្ខណៈលម្អិតជាក់លាក់ ឬពុំបំពេញតាមបទដ្ឋាននៃភស្តុតាងចាំបាច់ ឬគ្មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ។ ក្នុងករណីបែបនេះ អង្គជំនុំជម្រះពុំអនុញ្ញាតឲ្យភាគីដាក់សារណាតបឡើយ ប្រយោជន៍ដើម្បីកាត់បន្ថយពេលវេលាក្នុងការសម្រេច កាត់បន្ថយបន្ទុកក្នុងការបកប្រែភាសា និងរក្សាបាននូវការជំនុំជម្រះមួយដែលប្រព្រឹត្តទៅដោយឆាប់រហ័ស។

មេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានសន្និដ្ឋានដោយពុំត្រឹមត្រូវថា ចៅក្រម និងមន្ត្រីបុគ្គលិកកម្ពុជានៃអង្គជំនុំជម្រះមិនអាចចាត់ការបណ្តឹងណាមួយបានឡើយ លុះត្រាតែឯកសារទាំងអស់ពាក់ព័ន្ធនឹងបណ្តឹងនោះមានជាភាសាខ្មែរ។ ចៅក្រមជាតិមួយចំនួននៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីបុគ្គ-លិកជាតិទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង មានសមត្ថភាពធ្វើការងាររបស់ខ្លួនដោយប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេស ហើយជាងនេះទៅទៀតចៅក្រម និងមន្ត្រីបុគ្គលិកជាច្រើន (ទាំងជាតិ និងអន្តរជាតិ) មានសមត្ថភាពធ្វើការងាររបស់ខ្លួនដោយប្រើប្រាស់ភាសាបារាំង។ ការប្រាស្រ័យទាក់ទង និងការប្រជុំពិភាក្សារវាងសមភាគីជាតិ និងអន្តរជាតិ (ដោយមានការបកប្រែផ្ទាល់មាត់ជាជំនួយតាមការចាំបាច់) មានជាហូរហែរជាប់ជាប្រចាំ។ ប្រការនេះញ៉ាំងឲ្យការសម្រេចលើសំណើនានាអាចធ្វើទៅបានឆាប់ៗតាមការចាំបាច់ បន្ទាប់ពីភាគីបានដាក់សំណើទាំងនោះមកអង្គជំនុំជម្រះ។

ថ្វីត្បិតអង្គជំនុំជម្រះសម្រេចឆ្លើយតបទៅនឹងសំណើសុំមួយនេះក្តី ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា "សំណើសុំការបញ្ជាក់បំភ្លឺ" ពាក់ព័ន្ធនឹងវិធីសាស្ត្រការងារ និងតារាងពេលវេលារបស់អង្គជំនុំជម្រះពុំមែនជាកម្មវត្ថុនៃសំណើមកអង្គជំនុំជម្រះឡើយ ហើយពុំធ្លាប់ត្រូវបានតុលាការជាតិ ឬតុលាការអន្តរជាតុបនីយកម្មណាមួយលើកយកមកពិនិត្យពិចារណាដែរ។ អង្គជំនុំជម្រះនឹងពុំពិចារណាលើសំណើសុំប្រភេទនេះតទៅទៀតឡើយ (ក្នុងនោះរួមមាន ចម្ងល់របស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី

E150

ដែលចោទប្រកាន់អំពីការពន្យារពេលពុំត្រឹមត្រូវពាក់ព័ន្ធនឹងសំណើសុំផ្សេងៗដែលអង្គជំនុំជម្រះកំពុងពិចារណា)។